AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com




CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com

# ច្បាប់ក្រមង៉ុយ

- ច្បាប់ល្បើកថ្មី
- ច្បាប់កេរកាលថ្មី
- សេចក្ដីរំលឹកដាស់តឿន
- ពាក្យកាព្យប្រដៅជនប្រុសស្រី

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



## អារម្ភកថា

ច្បាប់ក្រមង៉ុយនេះកាលបោះពុម្ពលើកមុនៗ ចែកចេញជាបីសៀវភៅ គឺសៀវភៅទី១ មានច្បាប់ល្បើកថ្មី និងកេរកាលថ្មី. ទី២ សេចក្តីដាស់តឿន និងទី៣ពាក្យកាព្យប្រដៅជនប្រុសស្រី ។ នៅគ្រាបោះពុម្ពលើកទី៦នេះ ដោយនិយមតាមសេចក្តីស្នើពីមជ្ឈដ្ឋានអ្នកសិក្សាជាច្រើននាក់ដែលសុំអោយយើងផ្តុំគ្នាយកច្បាប់នេះមករួមគ្នាជាសៀវភៅមួយ ត្បិតទុកអោយនៅដោយឡែកៗជាកូនសៀវភៅតូចៗនោះនាំអោយរប៉ាត់រប៉ាយ ពិបាកថែរទាំ ។ យោបល់នេះត្រឹមត្រូវណាស់ ទើបយើងសម្រេចប្រមូលផ្តុំបានជាសៀវភៅមួយនេះឡើង ។

ចំពោះពាក្យពេចន៍ កាព្យឃ្លោងទាំងអស់នៅក្នុងច្បាប់ទាំងប៉ុន្មាននេះ យើងគ្មានប៉ះពាល់កែប្រែសោះឡើយ សម្រួលតែរបៀបតម្រៀបឃ្លាល្បះអោយមានលំនាំទៅតាមបែបកាព្យត្រឹមត្រូវប៉ុណ្ណោះ ។

គោលបំណងធំរបស់យើងខ្ញុំមួយទៀត គឺការចង់រក្សាស្នាដៃដ៏មានតម្លៃនៃលោកតាកវី **ភិរម្យង៉ុយ ឬក្រមង៉ុយ** ព្រោះពាក្យសំដីរបស់លោកក្នុងនេះទាំងអស់សុទ្ធតែមានន័យទូលំទូលាយ ហើយប្រកបដោយខ្លឹមសារល្អណាស់មិនចេះហួសសម័យកាលនោះផង តាំងពីគ្រាលោកសរសេររហូតសព្វថ្ងៃនៅតែមានន័យត្រូវគួរនិងធ្វើគតិទូន្មានខ្លួនបាន ។

ឆ្លៀតឱកាសនេះ ពុទ្ធសាសនបណ្ឌិតសុំសម្តែងគារវកិច្ចដ៏ជ្រាលជ្រៅចំពោះវិញ្ញាណក្ខន្ធនៃលោកកវីដ៏ឆ្នើមនេះផង ។

ភ្នំពេញ ខែ សីហា ឆ្នាំ ១៩៧២

**ពុទ្ធសាសនបណ្ឌិត្យ**

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



# សេចក្តីរំលឹកដាស់តឿន

អ្នកព្រះភិរម្យភាសា អ៊ឹ
លើកដៃទាំងគូប្រណម្យផ្ទង់
បង្គំព្រះពុទ្ធគ្រប់ព្រះអង្គ
ព្រះធម៌ព្រះសង្ឃប្រសើរសាយ ។
ព្រះគុណព្រះគ្រូឧបជ្ឈាយាចារ្យ
មាតាមិតាបង្កើតកាយ
បង្កើតប្រាជ្ញាថ្លាវែងឆ្ងាយ
ខ្ញុំសូមអធិប្បាយចែកពាក្យជូន ។
ព្រះពុទ្ធសករាជព្រះសាសនា
អតិកន្តាកន្លងធូន
ពីរពាន់បួនរយចិតសិបបួន
ជូនខែនឹងថ្ងៃគ្មានកន្លង ។
ដើមឆ្នាំមមែក្នុងត្រីស័ក
ពិសាខភ្លៀងធ្លាក់កាត់ទឹកម្តង
មួយរោចថ្ងៃសៅរ៍កើតសៅហ្មង
ឮពាក្យអ្នកផងទាស់ទែងគ្នា ។
មិនបានកាប់ចាក់ដល់បាក់បែក
ថ្ងៃនេះជជែកថ្ងៃស្អែកជា
ចាក់ដោតរាលរោលពោលពណ៌នា
និន្ទាដៀលត្មះចាស់បុរាណ ។
ពួកចាស់ដៀលត្មះអ្នកប្រាជ្ញថ្មី
រឿងធម៌បាលីស្តីប្រមាណ
ប្រមាថទៅមកមិនឈប់ខាន
ហាមប្រាមមិនបានមិនបាត់មាត់ ។
ព្រះធម៌ត្រះពុទ្ធតែមួយអង្គ
លោកសង្ឃបួសរៀនមានដោយវត្ត
សង្ឃខ្លះចេះស្ទើរមិនចាំស្ទាត់
ភ្លើៗសូត្រភ្លាត់មិនត្រូវខ្យល់ ។
គេប្រាប់ថាខុសប្រកាន់ខឹង
មិនដឹងថាខ្លួនរៀនមិនដល់
មិនដែលសួរគេព្រោះមិនឆ្ងល់
សម្គាល់ថាខ្លួនត្រូវមិនខុស ។
អ្នកប្រាជ្ញលោកសូត្រចំបាលី
ថាគេធម៌ថ្មីស្តីបន្ទុះ
បន្ទោសទៅមកឆ្លើយឆ្លងឈ្លោះ
មិនព្រមចំណុះខុសចំណាំ ។
ចំណែកចំណេះចេះរាល់ខ្លួន
បារាជិកបួនវិន័យប្រាំ
មហាវគ្គចុល្លវគ្គអាទិកម្ម
ព្រះសង្ឃគ្មានផ្តាំអោយឈ្លោះគ្នា ។
ផ្តាំអោយតែកាន់សិក្ខាបទ
អ្នកបួសរាល់វត្តត្រូវសាមគ្គា
ព្រះពុទ្ធរូបរាល់វិហារ
វន្ទាគោរពរាល់យប់ថ្ងៃ ។
នមស្ការបង្គំធម៌បីបទ
សូត្រហាហបមាត់នឿយដៃជើង
មិនដឹងប្រាកដរតនត្រ័យ
មិនចេះសង្ស័យសួរអ្នកណា ។
អ្នកប្រាជ្ញលោកសូត្រចំបាលី
ប្រែចេញសេចក្តីអោយពិស្តារ
អ្នកខ្លៅមិនស្គាល់តាមពុទ្ធដីកា
គេថាខ្លួនប្រុសប្រកាន់ខឹង ។

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ធម៌សម្ពុទ្ធសូត្រលាន់ៗ
ជឿជាក់ថាចេះចប់ប៉ុណ្ណឹង
ចេះហើយមិនដឹងថាខ្លួនខុស
បាលិច្រឡំពាក្យនិស្រាយ
គេថាសូត្រធម៌មិនចេះប្រែ
បើចេះប្រែផងបានចំណេញ
ចចេសទទឹងរឹងជជែក
ម្ចៅៗ(២) សត្រូវនឹងធម៌ព្រះ
មានកាលត្រឡប់ជាគថ្លង់
ពីព្រោះមិនស្ដាប់ប្រាជ្ញប្រដៅ
ប្រសិនបើឱនខ្លួនខ្លបខ្លាច
ធម៌អាថ៌អ្នកណានឹងចេះចប់
ទម្លាក់អោយទាបសុភាពវ័យ
ព្រះអភិធម្មជាមាំមួន
ពាក្យពីបុរាណជាពាក្យងាយ
ឯពាក្យគម្ពីរទើសចង្អៀត
អោយបែកគំនិតគិតច្រើនផ្លូវ
គេប្រាប់ថាខុសគួរឈប់ខាន
ព្រះឱស្ឋព្រះអង្គទ្រង់ទេសនា
ព្រះសូត្រវិន័យលោកលៃលក
ពាក្យពិតប្រាកដបទបាលី
គួរស្ដាប់អោយស្ដែងសិនកុំថា
តម្រាបុរាណយូរអង្វែង
អ្នកប្រាជ្ញជំនុំឃើញខុសណាស់
យ៉ាងធម៌ «តិរោក» ពីបុរាណ
សូត្រលាយចម្រុះខុសអក្ខរា
អ្នកប្រាជ្ញឃើញខុសច្រើនអន្លើ

ព្រះពុទ្ធវយពាន់ខ្លះមិនដឹង
មិនប្រឹងរៀនប្រែបកបរិយាយ ។
មិនព្រមចំណុះអ្នកប្រាជ្ញប្រាយ
នឹកស្ដាយបែបចាស់មិនផ្លាស់ចេញ ។
បានបុណ្យខ្លះដែរតែមិនពេញ
ខ្លួនរឹតទន្ទេញតែបែបចាស់ ។
ប្រកឹងប្រកែកប្រកួតម្នះ(១)
ជាតិក្រោយក្រឡាស់ជាល្ងង់ខ្លៅ ។
មម៉ែងមម៉ង់ឆ្កួតមួម៉ៅ
ហ្នឹងហៅចេះហើយមិនប្រសប់ ។
អ្នកប្រាជ្ញកាលណាលោកនឹងស្ងប់
កុំកាន់ទម្លាប់ទម្លោយខ្លួន ។
ព្រះសូត្រវិន័យធំជាងក្បួន
នេះហើយប្រធួនគួររៀនទៀត ។
ពាក្យក្បួនទូលាយស្រណុកជ្រៀត
គួរឆ្លៀតជ្រើសរកយកអោយបាន ។
មួយខុសមួយត្រូវជាពីរស្ថាន
ឃើញត្រូវប៉ុន្មានប្រមូលយក ។
អ្នកប្រាជ្ញថែងចារចងទុកមក
ប្រែសព្ទសៀតសឹកច្រើនប្រការ ។
ប្រែចេញសេចក្ដីឃើញពិស្ដារ
កុំអាងតម្រាតម្រាប់ចាស់ ។
មិនលែងច្រឡំមានលើសខ្វះ
ចោលខ្លះទុកខ្លះដោយពិស្ដារ ។
មិនដឹងជាបានពីគ្រូណា
មិនបានជាការប្រយោជន៍អ្វី ។
រះរើរៀបចំផ្សំបាលី

---

(១.២) ដែលត្រឹមត្រូវគឺ : មានះ - មិននៅ ។ ប៉ុន្តែនេះនិយមតាមសម្ផស្សកាព្យ ។

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



អ្នកខ្លៅហៅធមិតិរោកថ្មី
សម្តីបែបឡុកចំអកខឹង ។
សង្ខេបរឿងសូត្រធម៌ត្រូវខុស
កូនចៅប្រុស១គួរខំប្រឹង
ប្រឞរកអ្នកប្រាជ្ញប្រិតអោយដឹង
សម្លឹងអក្ខរាអោយប្រាកដ ។
ប្រការមួយទៀតចាស់ជាន់មុន
ធ្វើបុណ្យអភិសេកបែបច្រើនបទ
ច្រើនបែបរាប់អានគ្មានកំណត់
សន្មតថាធ្វើតាមបុរាណ ។
អាចារ្យមួយប៉ែកអភិសេកខ្និល
បង្ខិលពពិលរំពេចបាន
អាចារ្យមួយថាធ្វើតាមបាន
លំអានគម្ពីរបឋមគ្រាស់ ។
ទេសទសជាតក៏ចប់អភិសេក
ព្រឹកស្អែករៀបចំមធុបាយាស
មានមារលើកពលច្បាំងដេរដាស
ធ្វើច្រាសត្រឡប់ក្រោយជាមុន ។
បើធ្វើអោយត្រូវតាមសាស្ត្រា
នាងនាថសុជាតាគេមានគុណ
ថ្វាយមធុបាយាសព្រះមានបុណ្យ
និមន្តទៅផ្សងបីដងគ្រាស់ ។
ទេវតាផ្អើលចុះពេញផែនដី
គ្រប់ទិសប្រាំបីមីរដេរដាស
កក្រើកញាប់ញ័រទាំងអាកាស
អរណាស់ថ្វាយសព្ទសាធុការ ។
ហេតុនេះអ្នកចេះចាំនិទាន
ធ្វើរោងធ្វើរានថ្វាយទេវតា
អ្នកប្រាជ្ញចេះថ្មីស្រដីថា
អាចារ្យនាំធ្វើខាតប្រយោជន៍ ។
អាកាសទេវតានៅឋានខ្ពស់
គេខ្ពើមជាតិមនុស្សក្លិនអាសោច
ឧស្សាហ៍ដាក់នំអោយហិនហោច
ចំណេញស្រមោចចោមរោមស៊ី ។
អាចារ្យមួយទៀតចេះរៀបចំ
ប្រណមសំពះក្រុងពាលី
ព្រះឥសូរព្រះនារាយណ៍មានរិទ្ធី
ពេញទីចោលត្រៃសរណគមន៍ ។
ចំណីចំណែកចែកដាក់ពៃ
ចំណេញបានឆ្អែតវាស៊ីនំ
នាងហ៊ីងធរណីថាជាធំ
សូមសុំទឹកដីសាងកុសល ។
អាចារ្យជាន់ចាស់ដោះសង្ស័យ
ថារតនត្រ័យគេតំកល់
តម្កើងលើកឡើងជាដើមផល
ប្តឹងផ្តល់ទេវតាជាសក្សី ។
សសង្ខារិករលឹកគុណ
ធ្វើបុណ្យអភិសេកព្រះពុទ្ធថ្មី
បូជាភ្ញីផ្កាស្លាបារី
គ្រប់ទិសប្រាំបីសឹងអោយមាន ។
អភិសេកព្រះពុទ្ធតាំងកសាង
តំណាងព្រះពុទ្ធដ៏ទ្រង់ញាណ
រំលឹកទេវតាជាប្រធាន
ប្រាថ្នានិព្វានស្ថានផុតទុក្ខ ។
ថាបើទេវតាខ្ពើមចំណី
ស្អប់ស្លាបារីមិនចង់ជក់
បិសាចភ្លើ១មិនលែងភ្លក់
អារក្ខទេវតាមិនលែងសោយ ។

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



នំនែកចំណីឆ្អែតស្កប់ស្កល់ សេសសល់បានប្រេតគ្នាស៊ីក្រោយ
ស៊ីគ្រាន់រួចរស់ព្រោះគេអោយ បានដោយមគ្គផលកុសលដារ ។
លោកសូត្រតិរោកតែរាល់ព្រឹក យំកិញ្ចិច្រួចទឹកថែមយថា
បញ្ជូនអានិសង្សដល់ដូនតា ប្រាថ្នាដូចម្តេចក៏សឹងបាន ។
ក្រែងដូនតាណាទៅជាប្រេត ឬមួយអណ្តែតជាតិរច្ឆាន
លើសខ្វះប៉ុណ្ណោះខ្វះប៉ុន្មាន រាប់អានទេវតាប្រាថ្នាសុខ ។
ថាបើទេវតាមិនព្រមសោយ កុំអោយតែខុសចុះនរក
នរូកើតភាន់ផុតក្នុងភក់ វិវក់ក្នុងវាលវដ្តសង្សារ ។
មិនដាច់សង្ស័យដូចអរហត្ត លោកកាត់កាមគុណនិងតណ្ហា
ត្រង់ភ្លឹងមិនងាកពឹងទេវតា ប្រាថ្នានិព្វានគ្មានត្រឡប់ ។
ឃើញឆ្លងមិនផុតភពទាំងបី ធម៌អាចិបាលីចេះមិនចប់
មិនចោលសីល៥ កម្មបថ១០ រាវរៀបអោយសព្វកុំអោយសល់ ។
សម្បត្តិសួគ៌សុខកើតពីទាន ឈោងយកនិព្វានឈានមិនដល់
មិនដើរហួសសោតាមគ្គផល តម្កល់និព្វានទុកដោយឡែក ។
នេះចប់ចម្លើយអ្នកប្រាជ្ញចាស់ ប្រាជ្ញថ្មីចង់ឈ្នះប្រឹងប្រកែក
ប្រាកដនិព្វានជាស្ថានឯក ចំណែកសោតាក្នុងតែបាន ។
ជ្រះថ្លាធ្វើបុណ្យក៏ធ្វើចុះ ទានណាខាតខុសត្រូវអោយខាន
អារុក្ខអារក្ខកុំរាប់អាន ជាស្ថានទាបថោករកធ្វើអ្វី ។
សង្ខេបរឿងសូត្រធម៌ខុសត្រូវ កូនចៅស្តាប់ចុះទាំងប្រុសស្រី
អ្នកប្រាជ្ញពួកចាស់និងពួកថ្មី គប្បីចូលចិត្តជឿពួកណា ។
បើរឿងសូត្រធម៌អាចិបាលី គួរចូលប្រាជ្ញថ្មីខំសិក្សា
ប្រយោគប្រធានមានមត្រា រាជការបានធីប្រឡងជាប់ ។
ប្រាជ្ញចាស់ជាន់មុនធ្វើបុណ្យទាន ធ្វើវានទេវតាដោយសាធ្លាប់
អ្នកឆោតល្ងង់ខ្លៅគ្នាខ្លាចងាប់ អាចារ្យបង្គាប់គ្នាធ្វើទៅ ។
បើបែជាខានមិនបានសុខ មិនបានធ្លាក់ចុះនរកជ្រៅ
បើធ្វើទេវតាមិនជ្រកនៅ ស្ថានគេសន្ធៅសន្ធឹងហោះ ។
ហេតុនេះគួរគិតគួររំពឹង ជញ្ជឹងកុំអោយសល់ចន្លោះ
ចាស់មុនមានគុណរាប់មិនអស់ មិនអោយចោលសោះក៏មិនបាន ។
គួរគិតអោយគ្រប់សព្វអន្លើ គួរធ្វើឬគួរបង្អង់ខាន

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



បើធ្វើមិនខាតបង់ប៉ុន្មាន　　បើខានក៏គ្មានទោសទាស់អ្វី ។
ប៉ុន្តែមិនបាត់ពាក្យចាក់ដោត　　ដ្បិតមនុស្សច្រើនឆោតទាំងប្រុសស្រី
ពោលថាធ្វើបុណ្យតាមប្រាជ្ញថ្មី　　អាយុថយខ្ចីជាងដូនតា ។
ពាក្យនេះសង្ខេបស្លេះមួយប៉ែក　　មានឈ្មោះប្រកែកច្រើនប្រការ
មិនចាំប្រាកដគម្ពីរណា　　ពោលថាទឹកដីនេះគ្មានគុណ ។
អ្នកប្រាជ្ញនាំអោយអ្នកខ្លៅឆ្ងល់　　សាយសុសសួរដល់ពួកអ្នកមុន
អ្នកមួយវេរារង់រែកពុន　　មិនទាន់ចូលស៊ុនស៊ីប៉ម្នាង១ ។
អ្នកក្រោយបណ្តោយសួរអ្នកមុន　　ថាដីមានគុណប៉ុន្មានយ៉ាង
សម្គាល់គោលអ្វីជាតឹកតាង　　មានអាងឃើញក្នុងគម្ពីរណា ។
អ្នកម្ខាងថាអាងនគរកាយ　　បរមត្ថអធិប្បាយក្នុងសាស្ត្រា
ធាតុទឹកតួ ៩ អង្គអក្ខរា　　ជាគុណមាតាពីរដណ្តាប់ ។
ធាតុទឹករំលឹកពីសេម្ហំ　　វកំ យកនំ រហូតចប់
ធាតុដី កេសា មសំ សព្វ　　បញ្ចប់ បិត្តំ គុណបិតា ។
អ្នកចេះបិដកឆ្លើយបីដង　　ថានោះជាកងពួកកេសា
ហៅធម៌អាចម៍នោមក៏ល្មើមល្មា　　អ្នកណារំលឹកគ្មានប្រយោជន៍ ។
អ្នកមួយថាភាវនាកុំឈប់　　ជាទីអសុភផ្លូវអសោច
អសារឥតការស្លាប់ជាខ្មោច　　គេដុតឆេះខ្លោចគ្មានខ្លឹមសារ ។
គួរគិតកុំស្តាយកុំស្រណោះ　　រូបរាងទាំងអស់ជាអនិច្ចា
អនិច្ចំមិនទៀងល្បៀងសង្ខារ　　សង្ឃើមរូបានេះមិនបាន ។
សរសៃសាច់ស្បែកសង្កេតគ្រប់　　អាសាកអសុភកម្មដ្ឋាន
របស់ខាងក្នុងទាំងប៉ុន្មាន　　មុខជាមិនខានរលាយបាត់ ។
ទឹកដីខាងក្រៅក៏មានគុណ　　ព្រោះដីកើតមុនទើបកើតសត្វ
កើតសព្វរូបកាយអធិប្បាយកាត់　　លើកឡាត់លះឃ្លាអោយយ៉ាងខ្លី ។
គម្ពីរត្រៃភេទដើមសាសនា　　ត្រៃយុតត្រៃតាគ្រប់ជាបី
ព្រះពុទ្ធចេញសាងអាងទឹកដី　　សន្សំបារមីក្នុងភទ្ទកប្ប ។
ភទ្ទកប្បនេះមានព្រះពុទ្ធ៥　　បានរៀនចេះចាំជាសណ្តាប់
សម្តែងថាចុះនរកមួយកប្ប　　លោកប្រាប់ថាព្រោះជេរទឹកដី ។
អ្នកម្ខាងថាអាងរៀនសាស្ត្រា　　ប្រែអស់គាថាបទបាលី
ព្រះពុទ្ធទតគ្រប់ភពទាំងបី　　ត្រង់គុណទឹកដីមិនឃើញមាន ។

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



កេសាអក្ខរាទាំង ៥ តួ មិនគួរបើយកមកសន្និដ្ឋាន
យើងចេះដឹងដែរតែមិនហ៊ាន ដូចពោលបំពានហួយពុទ្ធដីកា ។
ពាក្យនេះអ្នកខ្លៅកើតសង្ស័យ សព្វថ្ងៃនៅក្នុងឧបេក្ខា
មិនទាន់ដាច់ស្រេចនៅខាងណា មិនឃើញពិស្តារស្តាប់មិនបាន ។
ម្យ៉ាងទៀតប្រាជ្ញថ្មីស្តីដៀលត្មេះ ចង្ហាន់ថ្វាយព្រះថាអោយខាន
ដ្បិតព្រះមិនឆាន់នៅពេញចាន របស់ប៉ុន្នាបានអាចារ្យ ។
របៀបរាប់បាត្រមានកន្ទោង មួយឈោងពីរឈោងហៅបាយដារ
បាយដាក់ហ្នឹងតើអោយអ្នកណា អសារឥតការឥតប្រយោជន៍ ។
ព្រះពុទ្ធមិនឆាន់មិនចេះស្តី យើងអាងបាលីឧទិសដល់
តម្កើងចង្ហាន់លើកតម្កល់ សេសសល់ប្រគេននេនសាមណេ ។
សមណៈបួសរៀនមានសីលដប់ ប្រសប់ប្រសើរគ្រាន់បើដែរ
បញ្ជូនមគ្គផលដល់ឪម៉ែ បង្វែរឧទិសតាមប្រាថ្នា ។
អ្នករេគំនិតគិតតែកាញ់ ចូលបទកំណាញ់ក្រៅតម្រា
ទុកស៊ីមាត់ឯងឆ្ងាញ់ពិសា ខ្លាចបានអាចារ្យស៊ីខាតទន់ ។
អ្នកម្ខាងថាអាងដាក់អោយប្រេត ដោយហេតុគ្នាឃ្លានគ្នាហិនហោច
គ្នាស៊ីខ្ទុះឈាមក្លិនអាសោច បិចបោចចែកទានគ្នាស៊ីផង ។
ប្រេតត្រូវជាញាតិធមិតិភោក គ្នាបានដើបមកព្រោះគេផ្សង
បានស៊ីដោយសារដារម្តងៗ បានដូចបំណងបំណាច់នឹក ។
ចង្ហាន់ថ្វាយព្រះត្រូវបូជា អាចារ្យវន្ទាសូត្ររំលឹក
ព្រះពុទ្ធខានគុណមុនលោកភិក្ខុ បាយទឹកជាទានមានមគ្គផល ។
ម្យ៉ាងទៀតប្រាជ្ញថ្មីស្រដីផ្តាច់ ថាពូនភ្នំខ្សាច់មិនបានបុណ្យ
ជីកដីល្បៀនភ្លែករែកតគ្រុន ដឹងបានជាគុណប្រយោជន៍អ្វី ។
នាំគ្នាអុជធូបហែទក្សិន អាចារ្យនោះឆ្អិនខាងបាលី
ហើយមានចេះធមិបំបួសដី មិនដឹងជាដីឆ្លើយថាម្តេច ។
អ្នកមួយថាពូនភ្នំខ្សាច់ស្នាង តំណាងចេតិយព្រះសរពេជ្ញ
ព្រះសារីរិកធាតុយើងមិនភ្លេច ដ្បិតបុណ្យយើងតិចទៅមិនដល់ ។
បើធ្វើដោយវាលកណ្តាលថ្ងៃ គង់ជាប់និស្ស័យបានកុសល
បើដើមពោធិ៍ពិតរីតបានផល តម្កល់ដើមពោធិ៍យកជាម្លប់ ។
ពូនភ្នំតម្កើងពោធិព្រឹក្ស រំលឹកដល់អង្គព្រះចមភព

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ច្រះក្តារ ៤ ផ្ទាំងបង្ខាំងផ្ទប់ កុំអោយកំពប់ហៀរហូរដី ។
បើចេះរំលឹកបានបុណ្យណាស់ ជឿចុះប្រាជ្ញចាស់កុំជឿថ្មី
ប្រាជ្ញចាស់ក៏ចេះប្រែបាលី បរលោកលោកីយក៏ចាស់ដឹង ។
ចាស់ម្យ៉ាងចាស់ពិតគំនិតពាល ចាក់ដោតរោលរាលនាំក្មេងខឹង
ចាស់ម្យ៉ាងផឹកស្រាក្លាស្រវឹង ចាស់ហ្នឹងហៅក្មេងក៏សឹងបាន ។
ចាស់ជាន់ពីមុនច្រើនក្លាចច្បាប់ ធ្វើតាមតម្រាប់ចាស់បុរាណ
បុរីនគរធ្លាប់រាប់អាន តែខានខ្លាចខុសក្បួនតម្រា ។
ច្រើនជឿតម្រាប់ក្បួនលោកីយ មានកូនប្រុសស្រីត្រូវរៀបការ
សម្លាប់ជ្រូកមាន់ស៊ីហ៊ឺហា ផឹកស្រាលានភ្នែកជជែកឈ្លោះ ។
បណ្តោយអោយយកគ្នាទទេ មេបាធ្វើគេក្រែងមិនរស់
នាំកូនសែនខ្មោចអសោចឈ្មោះ ពីព្រោះមានប្តីមិនរៀបការ ។
រៀបកិច្ចមង្គលមានច្រើនយ៉ាង ពួកចាស់ច្រើនអាងក្បួនតម្រា
បើតាមតម្រាយព្រះសូត្រថា មេបានាំកូនចុះនរក ។
បុត្តទារស្ស សង្គហោ ហីនោ គាមោ ធមិអ្នកស្រុក
សង្គ្រោះកូនផុងទៅក្នុងភក់ ហ្នឹងហៅអាពុកពន្លិចកូន ។
បើធ្វើមង្គលអោយរួចបាប រួចពារជរាបអស់តាដូន
មង្គលយ៉ាងល្អបរិសុទ្ធសូន្យ ប្រមូលបងប្អូនស៊ីម្ហូស្លា ។
ជ្រូកមាន់កុំចាំបាច់សម្លាប់ តែសាកមានស្រាប់ទិញពីផ្សារ
ផ្សំកូនប្រុសស្រីតាមមេបា អាចារ្យប្រមូលអស់ចាស់ទុំ ។
ប្រុសស្រីអង្គុយកាន់ពពិល បង្វិលប្រាំបួនដណ្តប់ជុំ
ធ្វើកិច្ចមង្គលក្នុងជំនុំ ផ្សំផ្គុំកូនប្រុសនិងកូនស្រី ។
ចាស់ៗធ្វើច្រើនធ្វើក្នុងឆោត ចង់អោយគេកោតនាលោកីយ
យើងធ្វើយ៉ាងតិចក្រឡិចខ្លី បានប្តីប្រពន្ធដូចៗគ្នា ។
ហៅកូនសង្គ្រោះម្តាយអាពុក រួចទោសរួចទុកអស់មីងមា
អាពុកសង្គ្រោះគ្មានវេរា អាពាហ៍វិវាហមង្គល ។
មិនគួរបង្គាប់អោយកោរជុក ហេតុម្តាយអាពុកនាំវរល់
អាចារ្យតែងក្បួនអោយអំពល់ ពន្យល់អ្នកល្ងង់អោយបង់ទ្រព្យ ។
អ្នកខ្ជិលគេជឿសីលមាំមួន ពាក្យក្បួនតម្រាគេមិនរាប់
គេថាមិនរស់ពីព្រោះធ្លាប់ មិនងាប់ពីព្រោះមិនធ្វើធ្មេញ ។

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



យ៉ាងដូចចិនយួននៅដាក់ផ្សារ
កើតឡើងដុះសក់មិនកោរវិញ
ប៉ុន្តែពួកចិនល្មោភស៊ីសាច់
ខ្មែរៗប្រហែសខ្ជះខ្ជាយជ្រក់
ហេតុតែជាខ្មែរសម្បុរខ្មៅ
រកស៊ីមិនឆ្អែតជឿសែចិន
១កើតអាស្រ័យសម្លាប់មាន់
រៀបសែនព្រះភូមិតាមបុរាណ
ហ្អឹងហៅចាស់ឆោតនាំក្មេងព្រើល
អារ័ដេងព្រះភូមិមានឈ្មោលញី
មានជូនដូនតាទៅស្រុកប្រែត
សំពះអារក្ខជួរខាងឪ
ថ្វាយចេកថ្វាយស្រាជារង្វាន់
កូនចៅអើយជឿពុទ្ធដីកាចុះ
រូបសុខដោយសារតែផលបុណ្យ
ជាតិនេះអាយុអង្វែងឆ្នាំ
អោយចេះពិចារណាចិត្តឯងផង
កុំផ្ញើរូបកាយនឹងអារក្ខ
បើចង់អាយុវែងយឺនយូរ
បើចង់រកស៊ីសុខសប្បាយ
នមស្ការបង្គំពេលល្ងាចព្រឹក
កុំថាធមិណាថោកណាថ្លៃ
កុំអោយមន្ទិលធមិថ្មីចាស់
រាជការជំនុំរួមគំនិត
តម្កលសីលប្រាំ សីលប្រាំបី
ផ្ទាត់ផ្ទៀងខ្លាចល្បែងព្រះពុទ្ធដីកា
ជំនុំបោះពុម្ពដាក់ក្រដាស
អោយបានរៀនសូត្រច្រើនតទៅ
សព្វថ្ងៃអ្នកខ្លៅស្អប់អ្នកប្រាជ្ញ

ស្រុកស្រែចំការក្រុងភ្នំពេញ
រវល់ដូរទិញអង្គុយលក់ ។
តមដាច់មិនដែលស៊ីព្រហាក់
ទូលស្រូវកន្ត្រក់ទៅដូរចិន ។
គំនិតគិតឆោតមិនសូវឆ្អិន
អាចិកវាកិនទាទាល់បាន ។
ចំអិនគ្រប់គ្រាន់ដូសដាក់ចាន
ថាខានខុសក្បួនប្រពៃណី ។
ហែកមាត់មាន់មើលចង្កាពីរ
ថាសែនរកស៊ីបានផលស្រូវ ។
បណ្តែតសំប៉ាន់ច្រានសំពៅ
ខាងម៉ែក៏ត្រូវមិនសូវខុស ។
ខ្មោចចូលជិះជាន់រូបស្រីប្រុស
រួចស្លាប់ពីព្រោះតែផលកម្ម ។
កាលជាតិពីមុនខ្ជាប់សីល៥
កូនចៅអ្នកចាំជឿអោយជាក់ ។
ស្តាប់ធមិម្តងៗគួរអោយភ្ញាក់
ក្រែងធ្លាក់ទៅក្នុងចតុរាបាយ ។
គោរពគុណគ្រូអាពុកម្តាយ
ផ្ញើកាយនឹងគុណរតនត្រ័យ ។
ភាវនារំលឹករាល់យប់ថ្ងៃ
សង្ស័យត្រូវសួររាជបណ្ឌិត ។
មួយធមិក្រដាសមួយស្លឹករឹត
រិះគិតតម្កើងព្រះសាសនា ។
អោយមនុស្សប្រុសស្រីរួមរក្សា
ពិនិត្យអក្ខរាយកត្រឹមត្រូវ ។
ជាការរហ័សធ្វើសៀវភៅ
ទុកនៅជាកេរ្តិ៍អង្វែងឆ្ងាយ ។
ពោលខ្លាំងតិតខ្លាចឮសុសសាយ

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ថាធម៌សៀវភៅធម៌ក្លែងក្លាយ　　អធិប្បាយខ្សឹបៗតែគ្នាឯង ។
អោយស្មៀមពីថ្ងៃនេះតទៅ　　ឯធម៌សៀវភៅផែនដីតែង
មិនមែនអ្នកប្រាជ្ញណាហ៊ានក្លែង　　ខ្លាចក្រែងរាជការចាប់ដាក់គុក ។
គម្ពីរស្លឹករឹតជាគំរូ　　តម្កល់ក្នុងទូចាក់សោទុក
គម្ពីរសៀវភៅប្រើគ្រប់មុខ　　ទំនុកបម្រុងក្នុងសាសនា ។
ចាស់ៗជាន់មុនមានគំនិត　　គម្ពីរស្លឹករឹតជួលគេចារ
ពុំនោះជាវគេដោយជ្រះថ្លា　　ច្រើនមានប្រាជ្ញាតិចអ្នកចេះ ។
ស្តង្គបបទបែបរឿងប្រដៅ　　ទូន្មានអ្នកខ្លៅឈប់ទុកស្លេះ
សុំក្រើនអ្នកប្រាជ្ញមានតម្រិះ　　កុំតិះដៀលត្មះចាស់ជាន់មុន ។
កុំថាចាស់ល្ងិតល្ងង់ល្ងីល្ងើ　　ក្រែងពារទៅលើអ្នកមានគុណ
កុំពោលថាចាស់ថោកថយធុន　　ក្រែងស៊ុនទៅលើគ្រូអាត្មា ។
ដ្បិតសិស្សនឹងគ្រូមិនអ្នកក្រៅ　　ជាក្មួយជាចៅជាជីតា
ជាសាច់ខាងមាតាឬបិតា　　ព្រោះកម្មវាចាខ្លះជាបង ។
ខ្លះត្រូវជាធំខ្លះជាមា　　ជាគ្រូឧបជ្ឈាយ៍បំបួសផង
ប្រដៅសព្វថ្ងៃវាយម្តងៗ　　ព្រោះលោកបំណងចង់អោយចេះ ។
ដល់ខ្លួនរៀនចាំដាក់បាលី　　ឡើងពាក្យសម្តីអាងតម្រិះ
តម្រូវខាងណោះខុសខាងណេះ　　ដៀលតិះថាគ្រូរខ្លួនឯងល្ងង់ ។
លោកគ្រូមិនដឹងប្រឹងតែអរ　　ខំផ្ញើអង្ករបាវការុង
ស្ករក្អមស្ករស្រាក់លាក់មិនគង់　　ចង់ថ្កើងពូជពង្សល្បីកេរ្តិ៍ឈ្មោះ ។
ខ្លួនចេះបន្តិចកំប៉ិចឡើង　　ចចើងចចេសជជែកឈ្លោះ
ចេះកប់ពពកយកកំពស់　　បន្ទុះបន្ទន់គុណទាបទៅ ។
បើចិត្តចង់ធំកុំចចើង　　គួរលើកតម្កើងគុណទុកនៅ
ទោសនោះធ្លាក់ចុះនរកជ្រៅ　　ម្តៅៗអោយបាបពីព្រោះមាត់ ។
ព្រោះមាននិទានពុទ្ធឃោសនា　　អាងចេះសាស្ត្រាគម្ពីរស្ទាត់
ថាចេះលើសគ្រូៗបំភ្លាត់　　បំប្លែងកំចាត់អោយទណ្ឌកម្ម ។
ប្រដូចនិទានតែប៉ុណ្ណោះ　　អស់លោកក៏ចេះបានរៀនចាំ
ផ្តួចផ្តើមមួយឃ្លាជាពាក្យផ្តាំ　　ដូចមានចំណាំចំណោទជូន ។
ទំនុកបុរាណមានប្រាជ្ញា　　ចេះចែងបញ្ហាសាស្ត្រាក្បួន
ទុកអោយអ្នកក្រោយដោះសំនួន　　បើគិតអោយមួនគួរមានភ័យ ។
ចំណោទថាសត្វបរោខា　　អង្គុយមែកឈើស៊ីផ្លែជ្រៃ

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



បុរសខុសជ្រុលគ្មានលក់ព្លៃ    បង់គោក្របីទាំងមេកូន ។
បុរសម្នាក់ទៀតឡើងដើមឈើ    បេះផ្លែខាងលើចែកបងប្អូន
ស៊ីផ្អែតបន្តិចភ្លេចគល់សូន្យ    បុរសម្នាក់បានកូនភ្លេចគុណម្តាយ ។
ចំណោទទីបីចំណែកនេះ    គួររិះអោយគិតកុំគិតឆ្ងាយ
កុំឆ្ងល់នឹងពាក្យពោលអធិប្បាយ    ប្រឹងគិតដោះស្រាយប្រាជ្ញាស្រាប់ ។
និយាយដើមត្រូដោយកំបាំង    មានខ្សឹបមានខ្លាំងពោលអង្អាប់
បង្អើលអោយអ្នកដទៃស្តាប់    បង្អន់ដូចកាប់គាស់ឫសគល់ ។
ស៊ីផ្លែទំផ្អែមតាមទុំខ្ចី    ឫសលិចក្នុងដីមើលមិនយល់
មិនយកដីចាក់កប់គុណទល់    អំពល់អោយបាបអំពីមាត់ ។
ពីមុនកាលកើតមានរូបកាយ    អ្នកម្តាយចិញ្ចឹមបានធំធាត់
នាំយកទៅទុកអោយនៅវត្ត    រៀនចេះចាំស្ទាត់បំភ្លាត់គុណ ។
ភ្លេចគោក្របីទាំងមេកូន    សាបសូន្យកុសលដែលមានមុន
សាងក្រោយសាងអោយតែខាតទុន    ពីព្រោះបាបស៊ុនស៊ិយពីចិត្ត ។
ពិចារណាគួរតែកោតខ្លាច    ខ្លួនបានជាប្រាជ្ញព្រោះគ្រូប្រិត
ប្រឹងប្រៀនប្រដៅច្បាប់ក្រមក្រឹត្យ    អាណិតដល់គុណធ្ងន់អនេក ។
អនាគតកាលទៅខាងមុខ    ចូរចាំចងទុកដល់ស្អែកៗ
កុំស្អប់ចាស់ថ្មីស្តីដោយឡែក    មើលចែកចាត់ចិត្តថ្លឹងអោយស្មើ ។
ធ្វើបុណ្យអោយស្មោះកុំរើស្នែគ្រ    បាលីបីថ្នាក់ចាំហើយតើ
មនោសេដ្ឋចិត្តប្រសើរ    ប្រសប់គ្រាន់បើធ្វើបុណ្យបាន ។
ប្រាជ្ញថ្មីធ្វើតិចធ្វើតាមចុះ    កុំថាគេខុសហើយឈប់ខាន
ប្រាជ្ញចាស់ច្រើនធ្វើតាមបុរាណ    ច្រើនលើសប៉ុន្មានបានដោយបទ ។
កុំធ្វើដោយរាប់អានស្រឡាញ់    ទុកជាកំណាច់ហួសកំណត់
កំណើតមគ្គផលជឿប្រាកដ    សន្មតថាបានច្រើនប្រការ ។
កុំធ្វើប្រកាន់ដោយយល់មុខ    ហៅបុគ្គលិកទានគ្មានផលា
តាំងចិត្តចុះផ្លូវឧបេក្ខា    រក្សារូបសុខដល់សួគ៌នាយ ។
សួគ៌នេះបើចង់អោយបានឆាប់ដល់    សាងមគ្គសាងផលកុំរាយមាយ
ឃើញគេខុសចិត្តកុំមើលងាយ    កុំពោលនិយាយកាន់ម្ខាងៗ ។
អ្នកប្រាជ្ញចេះថ្មីត្រូវដោយឡែក    ចំណែកប្រាជ្ញចាស់ត្រូវដោយយ៉ាង
កាន់យកទាំងពីរជាទីអាង    សន្សំខំសាងនឹងបានសុខ ។
ពីថ្ងៃនេះទៅនៅអោយនឹង    ស្ញៀមមាត់អោយឈឹងខ្លាចនរក

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ពីព្រោះឈ្មោះគ្នារៀងរាល់ស្រុក
មិនឈ្មោះពីរឿងគេរឿងកោះ
នេះឈ្មោះពីធមិចាស់ធមិថ្មី
បើក្តីពីស្រែចំការ
នេះក្តីពីធមិថ្មីធមិចាស់
ចៅក្រមសព្វថ្ងៃឧបាសក
កាត់ក្តីត្រូវច្បាប់អម្បាលម៉ាន
អាដែងមនុស្សម្នះរឹងចចេស
តែទុកវានៅវានាំវរ
សង្ខេបបែបបទរឿងប្រដៅ
អ្នកចេះសូត្រធមិមិនស្គាល់សព្ទ
ធ្វើបុណ្យធ្វើទានកុំចោលចាស់
សូត្ររៀនតាមបែបអ្នកប្រាជ្ញថ្មី
ធមិអាថិច្រឡំកំច្រឡោត
រួមចិត្តសះសាបានសុខសាន្ត
កុំអោយរវើរវាយរឺតរវងកម្ម
វស្សន្តរដូវត្រូវមនុស្សថា
មនុស្សភូតកុហកឆក់ឆបោក
ក្រលុយក្រកាក់ខ្ទះប្រាក់ចាយ
ភិរម្យខ្ញុំបាទដើមឈ្មោះ អ៊ូ
អាពុកឈ្មោះ អ៊ុក មានសក្តិងារ
ក្នុងខេត្តភ្នំពេញ ឃុំកំបូល
ជីតាខាងម្តាយឈ្មោះពញ្ញាម៉ុក
អ្នកម្តាយអាពុកបងប្អូនជិត
ដូនតាផ្សំផ្គុំជាតំណ
ពូជខាងអាពុកមានប្រាជ្ញា
ត្រកូលខាងម្តាយប្រាជ្ញាឆ្លាត
ខ្ញុំពួមនុស្សឈ្មោះពីធមិអាថិ
ខ្ញុំចាប់អធិប្បាយពុំសាយសព្ទ

បឹងថ្លុកត្រពាំងរាំងប្រេះដី ។
ឬទ្រព្យរបស់គោក្របី
ក្តៅចិត្តកើតក្តីរកចាញ់ឈ្នះ ។
ចៅក្រមសាលាងាយជម្រះ
នោះក្រែងតែព្រះទើបកាត់បាន ។
ចេះខ្ចេចបិដកព្រះកម្មដ្ឋាន
អ្នកក្តីមិនខានប្តឹងឧទ្ធរណ៍ ។
បានតែនិរទេសក្រៅនគរ
ជំហរតែរឹងទទឹងច្បាប់ ។
អ្នកល្ងីតល្ងង់ខ្លៅគួរតែស្តាប់
គួរគ្រាប់អ្នកប្រាជ្ញចេះបាលី ។
ចោលចេញទុកខ្លះក្បួនលោកិយ
កុំបីភ្លេចគុណចាស់បុរាណ ។
ពាក្យពោលចាក់ដោតអោយឈប់ខាន
នឹងអោយរុងរឿងរីកសាសនា ។
រាំងរឹងរាល់ឆ្នាំ៥វស្សា
រំជួលទេវតាក្តៅក្រហាយ ។
ឆ្នាំនេះស្រូវថោករាស្ត្រអត់បាយ
មហាជនទាំងឡាយកើតវេទនា ។
ពូជពង្សអម្បូរខ្មែរអ្នកជា
ចៅពញាធម្មាធារាមេស្រុក ។
ពូជពង្សត្រកូលម្ចាស់អង្គប៉ុក
គាត់ធ្វើមេស្រុកឃុំស្ពានថ្ម ។
ជីទួតមួយពិតពូជចិត្តល្អ
បង្កកើតមកជាខ្ញុំបាទ ។
ច្រើនចេះសាស្ត្រាចាំក្បួនខ្នាត
រូបរាងច្រើនស្អាតគ្មានគេស្អប់ ។
គិតក្រែងសាសនាប្រែត្រឡប់
សន្ធតថាចប់ម្លេះឯងហោង ៕

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel